# សេចក្តីប្រកាស និងអញ្ជើញសារព័ត៌មាន

## សិក្ខាសាលាអំពីសុវត្ថិភាពចំណីអាហារ ព័ត៌មានទីផ្សារ និងសេវាកម្មហិរញ្ញវត្ថុ

អង្គការទស្សនៈពិភពលោក សហការជាមួយសមាគមវារីវប្បករកម្ពុជារៀបចំសិក្ខាសាលាតាមប្រព័ន្ធពីចំងាយនៅថ្ងៃទី **១៩ ខែ សីហា ឆ្នាំ** ២០២១ ជាមួយកសិករចិញ្ចឹមត្រី និងអ្នកកែច្នៃត្រីដោយផ្តោតសំខាន់លើសុវត្ថិភាពចំណីអាហារ ព័ត៌មានទីផ្សារចែករំលែកដោយសមាគមវារីវប្បករ ផ្សារភ្ជាប់ជាមួយសេវាកម្មហិរញ្ញវត្ថុ ដោយមានទិសដៅអោយអាជីវករយើងទាំងអស់ផ្តោតសំខាន់រឿងអនាម័យក្នុងការកែច្នៃ ព័ត៌មានទីផ្សារត្រឹមត្រូវ និង សេវាកម្មហិរញ្ញវត្ថុផ្លូវការ។ គម្រោងអភិវឌ្ឍន៍វារីវប្បកម្មសម្រាប់និរន្តរភាពពាណិជ្ជកម្មនៅកម្ពុជានឹងផ្តល់ជាការយល់ដឹងជាក់លាក់អំពីសេវាកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ចម្រើន** ចំពោះកសិករចិញ្ចឹមត្រី អ្នកកែច្នៃត្រី អ្នកភ្ញាស់កូនត្រី អ្នកផ្គត់ផ្គង់ចំណី ដោយធ្វើអោយពួកគាត់មានភាពងាយស្រួលក្នុងការទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ និងប្រើវេទិការនេះការពិភាក្សារកដំណោះលើផលលំបាកកន្លងមក។

សេវាកម្មហិរញ្ញវត្ថុមានគោលដៅជួយសហគ្រាសខ្នាតតូច និងមធ្យមផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ចរបស់ពួកគាត់ដោយផ្តល់អោយ ជាចំណេះ ជំនាញ លើសេវាហិរញ្ញវត្ថុឈានដល់ការបង្កើនទំហំប្រាក់ចំណូលរបស់ពួកគាត់។ ដើម្បីជាការឆ្លើយតបជាមួយស្ថានភាព កូវីឌ១៩ អង្គការទស្សនៈពិភពលោក និងសមាគមវារីវប្បករកម្ពុជាចូលរួមគាំទ្រជីវភាពវារីវប្បករក្នុងការបន្សាំខ្លួនទៅនឹងស្ថានភាពដ៏លំបាកនេះ ដោយហិរញ្ញវត្ថុជាសេវាកម្មមួយដ៏សំខាន់។

**អង្គការទស្សនៈពិភពលោក សហការជាមួយសមាគមវារីវប្បករកម្ពុជាសូមអញ្ជើញសារព័ត៌មានទាំងអស់ចូលរួមក្នុងសិក្ខាសាលា**
**ពេលវេលា:** ថ្ងៃព្រហស្បត៍ ទី១៩ ខែសីហា ឆ្នាំ២០២១ ម៉ោង១០ ដល់ ១១:៤០ ព្រឹក
**តាមរយៈ:** ប្រព័ន្ធ តេលេក្រាម (Telegram)
**ទំនាក់ទំនង:** លោក អ៊ា តិចគង់ ទូរស័ព្ទលេខ ០៨៦ ៤០៩ ១៦៨

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចម្រើន** ជាគ្រឹះស្ថានមានការទទួលស្គាល់ពីកិច្ចការពារអតិថិជន (MFI) ដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមិនទទួលប្រាក់បញ្ញើ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចម្រើន ផ្តោតលើការគាំទ្រដល់សហគ្រិនខ្នាតតូចក្នុងការអភិវឌ្ឍសកម្មភាពបង្កើតប្រាក់ចំណូលរបស់គាត់ ហើយជាទូទៅធ្វើអោយប្រសើរឡើងនូវគុណភាពនៃជីវិត តាមរយៈការកែសំរួល និងបញ្ចូលគ្នានៃសេវាកម្មគាំទ្រហិរញ្ញវត្ថុ និងកម្មវិធីផ្សេងទៀតដែលមិនត្រូវការសាច់ប្រាក់។

**សមាគមវារីវប្បករកម្ពុជា** គឺជាសមាគមគាំទ្រសង្វាក់ផលិតកម្ម ដូចជាកសិករចិញ្ចឹមត្រី ភ្ញាស់កូនត្រី ចំណីរត្រី និងក្រុមហ៊ុនផលិតចំណីរ ដោយមិនប្រកាន់និន្នាការនយោបាយ និងសាសនា។

**គម្រោងអភិវឌ្ឍន៍វារីវប្បកម្មសម្រាប់និរន្តរភាព ពាណិជ្ជកម្មនៅកម្ពុជា (ខាស់)** គឺជាគម្រោងដែលទទួលបានការឧបត្ថម្ភថវិកា ពីក្រសួងកសិកម្មអាមេរិក ដើម្បីបង្កើនផលិតកម្មត្រីដែលមានតម្រូវការខ្ពស់សម្រាប់ទីផ្សារប្រទេសកម្ពុជា និង អភិវឌ្ឍន៍ផ្នែកឧស្សាហកម្មវារីវប្បកម្មប្រកបដោយនិរន្តរភាព ដែលអនុវត្តដោយអង្គការសណ្តែកសៀងអាមេរិកដែលជាដៃគូដឹកនាំ និង អង្គការទស្សនៈពិភពលោក ។

**អង្គការទស្សនៈពិភពលោក** គឺជាអង្គការគ្រឹះសាសនា សម្រប់ការអភិវឌ្ឍ តស៊ូមតិ សម្រាប់វិស័យកុមារ គ្រួសារ និងសហគមន៍ ក្នុងការជំនះនៃភាពក្រីក្រ និងស្វែងរកយុត្តិធម៌ ដែលមានអាស្រ័យដ្ឋាន ផ្ទះលេខ២០ ផ្លូវ ៧១ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌ ចំការមន ភ្នំពេញ។

ផ្ទះលេខ ៣៤ ផ្លូវ៣៣៥ កាច់ជ្រុង៥៦៨ សង្កាត់បឹងកក់២
ខណ្ឌទួលគោក ភ្នំពេញ
+(៨៥៥) ៧៨ ៨០៧ ១១៨ / ៧០ ៨៣៩ ៣០៩
CASTinCambodia